**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

លេខ : ២៨៧ សកបយ.

ភ្នំពេញ. ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ២០០១

# ប្រកាស
# ស្តីពី
# បែបបទចុះបញ្ជិកា ការផ្សព្វផ្សាយ និងការត្រួតពិនិត្យ ការអនុវត្តន៍អនុសញ្ញារួម

## រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ០២ / នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ១៩៩៧ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការងារ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី០៤ ខែ តុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។

## ស ម្រេ ច

**ប្រការ១.-** អនុសញ្ញារួមត្រូវសរសេរជាភាសាខ្មែរ ។ អនុសញ្ញារួមអាចបកប្រែជាភាសាបរទេសបាន ប៉ុន្តែករណីមានវិវាទស្តីពីការបកស្រាយខ្លឹមសារនៃអនុសញ្ញារួម គឺយកភាសាខ្មែរជាផ្លូវការចំពោះមុខច្បាប់ ។

**ប្រការ២.-** អនុសញ្ញារួមត្រូវបញ្ជាក់ច្បាស់អំពីដែនអនុវត្តរបស់ខ្លួន ។ ភាគីហត្ថលេខីត្រូវខិតខំអស់ពីលទ្ធភាព ដើម្បីដាក់បញ្ចូលទៅក្នុងអនុសញ្ញារួមនូវនីតិវិធីទាំងឡាយដែលទាក់ទងនឹងការផ្សះផ្សា ការដោះស្រាយវិវាទតាម

រយៈអាជ្ញាកណ្តាល និងការបកស្រាយអនុសញ្ញារួម ។

**ប្រការ៣.-** លើកលែងតែមានបទបញ្ញត្តិច្បាប់ផ្ទុយពីនេះ អនុសញ្ញារួម ឧបសម្ព័ន្ធ និងកិច្ចសន្យាបន្ថែមរបស់អនុសញ្ញារួម មានប្រសិទ្ធិភាពអនុវត្តមួយថ្ងៃបន្ទាប់ពីបានចុះបញ្ជិកានៅស្ថាប័នមានសមត្ថកិច្ច ។ ជនដែលបានចុះហត្ថលេខា ឬជាសមាជិកនៃអង្គការហត្ថលេខី មានកាតព្វកិច្ចអនុវត្តអនុសញ្ញារួមនេះ ។ និយោជកដែលដកសមាជិកភាពចេញពីអង្គការហត្ថលេខី ក្រោយពេលដែលអនុសញ្ញារួមចូលជាធរមាន នៅតែមានកាតព្វកិច្ចអនុវត្តអនុសញ្ញារួមនេះ ។

**ប្រការ៤.-** និយោជក ឬអង្គការរបស់និយោជក ត្រូវយកអនុសញ្ញារួម ព្រមទាំងឧបសម្ព័ន្ធ និងកិច្ចសន្យាបន្ថែមរបស់អនុសញ្ញារួមទៅចុះបញ្ជិកានៅមន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទាខេត្ត-ក្រុង បើអនុសញ្ញារួមបានចុះហត្ថលេខានៅខេត្ត-ក្រុង ឬនៅនាយកដ្ឋានអធិការកិច្ចការងារ បើអនុសញ្ញារួមបានចុះចុះហត្ថលេខានៅភ្នំពេញ ។ សំណុំលិខិតស្នើសុំចុះបញ្ជិកាមានដូចតទៅ :-

-ពាក្យសុំចុះបញ្ជិកា........................................................................................ ០១ ច្បាប់

-អនុសញ្ញារួម ឧបសម្ព័ន្ធ និងកិច្ចសន្យាបន្ថែមរបស់អនុសញ្ញារួម " បើមាន " ក្នុងមួយមុខ....... ០៥ច្បាប់ ។

**ប្រការ៥.-** បន្ទាប់ពីបានចុះបញ្ជិកាហើយ មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត-ក្រុង ឬនាយកដ្ឋានអធិការកិច្ចការងារ ត្រូវបញ្ជូនអនុសញ្ញារួម ឧបសម្ព័ន្ធ និងកិច្ចសន្យាបន្ថែមរបស់អនុសញ្ញារួមមួយមុខមួយច្បាប់ ទៅតំកល់ទុកនៅការិយាល័យក្រឡាបញ្ជីនៃតុលាការការងារ ឬការិយាល័យក្រឡាបញ្ជីនៃតុលាការខេត្ត -ក្រុង ក្នុងមូលដ្ឋានខ្លួនបើមិនទាន់មានតុលាការការងារ ។

**ប្រការ៦.-** និយោជកដែលជាប់ទាក់ទិននឹងអនុសញ្ញារួម ត្រូវផ្តល់សេចក្តីចម្លងនៃអនុសញ្ញារួម ឧបសម្ព័ន្ធ និងកិច្ចសន្យាបន្ថែមរបស់អនុសញ្ញារួម ដែលបានចុះបញ្ជិការួចហើយអោយប្រតិភូបុគ្គលិកមួយច្បាប់ម្នាក់ និងមួយច្បាប់ទៀតអោយការិយាល័យបុគ្គលិកនៃសហគ្រាស គ្រឹះស្ថានសំរាប់ការស្វែងយល់របស់កម្មករនិយោជិតទាំងអស់ ។ ទន្ទឹមនេះ និយោជកត្រូវបិទផ្សាយសេចក្តីជូនដំណឹងអំពីការធ្វើអនុសញ្ញារួមនេះនៅគ្រប់ទីកន្លែងធ្វើការរបស់កម្មករនិយោជិត និងកន្លែងផ្សព្វផ្សាយពត៌មានដល់កម្មករនិយោជិត ។ ជនគ្រប់រូបអាចស្វែងយល់ដោយឥតគិតថ្លៃអំពីអនុសញ្ញារួម ឧបសម្ព័ន្ធ និងកិច្ចសន្យាបន្ថែមរបស់អនុសញ្ញារួមនៅមន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត-ក្រុង ឬនាយកដ្ឋានអធិការកិច្ចការងារ ។ករណីចាំបាច់ គេក៏អាចសុំសេចក្តីថតចម្លងនៃឯកសារទាំងអស់នេះបាន ដោយគ្រាន់តែបង់ថ្លៃចំពោះការថតចម្លងប៉ុណ្ណោះ ។

**ប្រការ៧.-** អធិការការងារអាចចុះទៅត្រួតពិនិត្យការអនុវត្តន៍អនុសញ្ញារួម ដោយសាកសួរពត៌មានពីប្រតិភូបុគ្គលិក នាយកសហគ្រាស គ្រឹះស្ថាន ឬពីកម្មករនិយោជិតផ្ទាល់ ។

**ប្រការ៨.-** រាល់វិវាទដែលទាក់ទងនឹងការអនុវត្តន៍អនុសញ្ញារួម អាចអោយភាគីណាមួយប្តឹងទៅតុលាការការងារ ឬតុលាការខេត្ត -ក្រុងនៃមូលដ្ឋានដែលអនុសញ្ញារួមបានចុះហត្ថលេខា។ តុលាការអាចសំរេចអោយផ្តល់សំណងជំងឺចិត្តដល់ភាគីដែលមានការខូចខាត។ ប៉ុន្តែភាគីវិវាទអាចប្តឹងទៅអធិការការងារ មានសមត្ថកិច្ចនៅទីកន្លែងដែលភាគីកម្មករនិយោជិតធ្វើការ ដើម្បីធ្វើការផ្សះផ្សាជាមុនសិន។

**ប្រការ៩.-** ការចូលរួមអនុវត្តអនុសញ្ញារួមពីសំណាក់និយោជក ឬអង្គការវិជ្ជាជីវៈផ្សេងទៀត ក្រៅពីភាគីហត្ថលេខី និងសមាជិក ក្រោយពេលដែលអនុសញ្ញារួមនេះបានចុះហត្ថលេខារួចហើយក៏ដូចជាការបដិសេធអនុសញ្ញារួម ត្រូវអនុវត្តបែបបទដូចគ្នានឹងការចុះបញ្ជិកា និងផ្សព្វផ្សាយអនុសញ្ញារួមដែរ។

**ប្រការ១០.-** ប្រកាសរបស់ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជនលេខ ២៤៩ សកអ. ចុះថ្ងៃទី ១៤ ខែ សីហា ឆ្នាំ១៩៩៧ និងលេខ ១៩៧ សកអ.ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ១៩៩៨ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ១១.-** អនុសញ្ញារួមដែលបានចុះហត្ថលេខារួចហើយមុនការចេញផ្សាយនៃប្រកាសនេះក៏ត្រូវចុះបញ្ជិកា និងផ្សព្វផ្សាយអោយបានត្រឹមត្រូវតាមខ្លឹមសារនៃប្រកាសនេះផងដែរ។

**ប្រការ៦.-** ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**<u>ចម្លងជូន</u>**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ទីស្តីការគណៈរដ្ឋមន្ត្រី
-គ្រប់ក្រសួងពាក់ព័ន្ធ

" ដើម្បីជូនជ្រាប "

-អគ្គនាយកដ្ឋាន ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ
-គ្រប់មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត-ក្រុង

"ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"

-សមាគមនិយោជក
-សហព័ន្ធសហជីព

" ដើម្បីជ្រាប "

-គ្រប់បណ្តាញវិទ្យុ និងទូរទស្សន៍ "ដើម្បីជួយផ្សព្វផ្សាយ "
-រាជកិច្ច
-កាលប្បវត្តិ និងឯកសារ

អ៊ិត សំហេង